# វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ

# ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ភ្នំពេញ កម្ពុជា

# សុន្ទរកថាស្វាគមន៍ថ្ងៃទី ១

ដោយលោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

សូមគោរព៖

ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការក្រសួងបរិស្ថាន

ឯកឧត្តម លោកជំទាវ ដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយស លោក លោកស្រី ជាទីមេត្រី!

ក្នុងនាមក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ខ្ញុំមានកិត្តិយសក្នុងការស្វាគមន៍ឯកឧត្តម លោកលោកស្រី នៅក្នុងវគ្គនេះនៃវេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ។

ជាការចាប់ផ្តើម ខ្ញុំសូមអបអរសាទរគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលបានដឹកនាំការចាត់ចែងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ។ ការប្រកាសជាផ្លូវការនូវ*ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា* ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បង្ហាញពីចំណុចគោលដ៏សំខាន់មួយដែលបញ្ជាក់ពីការប្តេជ្ញាមុតមាំរបស់រដ្ឋាភិបាលក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ការចេញផ្សាយថ្មីៗនេះនៃ*របាយការណ៍វាយតម្លៃលើកទី៥ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ* សន្និដ្ឋានថា ការឡើងកំដៅផែនដីក្នុងរយៈពេលហាសិបឆ្នាំកន្លងមកនេះ ភាគច្រើនលើសលុបបង្កដោយសកម្មភាពរបស់មនុស្ស។ ការធ្លាក់ភ្លៀង និងរបបសីតុណ្ហភាពនឹងបន្តប្រែប្រួលនៅក្នុងបណ្តាទសវត្សរ៍ខាងមុខនេះ ដែលបង្កជាការគំរាមកំហែងមកលើកិច្ចប្រឹងប្រែងលុបបំបាត់ភាពក្រីក្រ។ គ្រោះមហន្តរាយធម្មជាតិដែលបង្កដោយអាកាសធាតុដែលកើតចេញពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត កាន់តែ

មានញឹកញាប់ជាងមុនរួចទៅហើយ និងកាន់តែខ្លាំងផងដែរ។និន្នាការនេះត្រូវបានគេរំពឹងថានឹងបន្តបង្កជាការប្រឈមសំខាន់ៗមកលើការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍និងការទ្រទ្រង់កំណើននៃសមិទ្ធផលនេះ។

*កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសចំនួនដប់ ដែលមានភាពងាយរងគ្រោះបំផុត ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។* សេចក្តីព្រាង*របាយការណ៍ជាតិលើកទី២ សម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC)* បង្ហាញថា សីតុណ្ហភាពជាមធ្យមក្នុងប្រទេសកម្ពុជាបានកើនឡើង០,៨ អង្សាសេ តាំងពីឆ្នាំ១៩៦០មក។ ការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ នឹងកាន់តែធ្វើឲ្យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធការផ្គត់ផ្គង់ទឹក ប្រព័ន្ធអេកូឡូស៊ី និងសុខភាព និងសុវត្ថិភាពរបស់មនុស្សប្រឈមនឹងហានិភ័យ។ ប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ និងក្រុមដទៃទៀត ដូចជា គ្រួសារដែលមានស្រីជាមេគ្រួសារ កុមារ មនុស្សចាស់ ជនពិការ និងសហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមដែលមានភាពងាយរងគ្រោះជាពិសេស។

*ភាពងាយរងគ្រោះរបស់កម្ពុជានៅចំពោះមុខការប្រែប្រួលអាកាសធាតុ មិនមែនដោយសារតែហានិភ័យអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែប្រទេសនេះនៅមានសមត្ថភាពបន្សាំក្នុងកម្រិតកំណត់ផងដែរបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀត*។ ប្រជាជនប្រមាណជា៨០% រស់នៅតំបន់ជនបទ ដែលភាគច្រើនធ្វើកសិកម្ម មានសមត្ថភាពបន្សាំ និងហេដ្ឋារចនាសម្ព័ន្ធកម្រិតទាប។ សេចក្តីព្រាង *របាយការណ៍ជាតិលើកទី ២ សម្រាប់ UNFCCC* ក៏បង្ហាញផងដែរថាជិត ៥០% នៃឃុំនៅកម្ពុជា ត្រូវបានចាត់ទុកថាស្ថិតក្នុងចន្លោះស្ថានភាពងាយរងគ្រោះ និងងាយរងគ្រោះបំផុតនៅចំពោះមុខវិសមរូបអាកាសធាតុ។

ការប្រែប្រួលអាកាសធាតុត្រូវគេដឹងថាជាការគំរាមកំហែងធំជាងគេមួយចំពោះការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែជាញឹកញាប់បំផុត ប្រការសំខាន់មួយត្រូវគេបំភ្លេច៖ *ការដោះស្រាយការប្រែប្រួលអាកាសធាតុគឺជាឱកាសមួយក្នុងចំណោមឱកាសធំបំផុតចំនួនបួនរបស់យើង។* ជំនាញខាងបច្ចេកវិទ្យាបំភាយកាបូនកម្រិតទាប និងការបន្សាំគឺជាអ្វីដែលត្រូវការជាខ្លាំង។ ប្រទេសនានាដែលវិនិយោគក្នុងដំណាក់កាលដើមដំបូងលើវិស័យទាំងនេះនឹងស្ថិតក្នុងស្ថានភាពរឹងមាំនៅក្នុងទីផ្សារថ្មីនេះ។ ប្រការសំខាន់បំផុតគឺ ការរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនៅក្នុងរាល់វិស័យទាំងអស់ដែលបានលើកឡើងដោយសម្តេច

នាយករដ្ឋមន្ត្រីនាពេលព្រឹកនេះផ្តល់នូវឱកាសដើម្បីបង្កើតគំរូនៃកំណើនសេដ្ឋកិច្ចដោយចីរភាពសម្រាប់កម្ពុជា ស្របជាមួយតុល្យភាពដែលត្រូវការជាចាំបាច់រវាងអត្ថប្រយោជន៍ខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

សូមអនុញ្ញាតឲ្យខ្ញុំគូសបញ្ជាក់អំពីវិធាននានា ដែលអាចពង្រឹងសមត្ថភាពដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ទីមួយ *ការរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និងការលើកថវិកាអភិវឌ្ឍន៍ជាតិ និងនៅមូលដ្ឋាន គឺជាគន្លឹះក្នុងការបន្សុាំ និងការវិនិយោគដែលធន់នឹងអាកាសធាតុ។* ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបែតងមានឆ្លុះបញ្ចាំងរួចមកហើយនៅក្នុងដំណាក់កាលនានានៃយុទ្ធសាស្ត្រចតុកោណដំហានទីបី។ ប្រការសំខាន់គឺវាត្រូវតែជាអាទិភាពទាំងនៅក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី*ក៏ដូចជានៅក្នុងដំណើរការកសាងផែនការសម្រាប់អង្គភាពនានានៅថ្នាក់ក្រោមជាតិផងដែរ។ ដូចដែលយើងបានជ្រាបហើយនោះ អ្វីដែលបានវាស់វែងតែងតែបានសម្រេច។ ដូច្នេះ វាមានសារៈសំខាន់ផងដែរក្នុងការដាក់អោយមានប្រព័ន្ធតាមដាននិងវាយតំលៃដើម្បីតាមដានសកម្មភាពអនុវត្តរបស់ផែនការទាំងនេះ។ ក្រុមទីភ្នាក់ងារសហប្រជាជាតិ បានចូលរួមជាមួយដៃគូនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់យើង ដើម្បីធ្វើឲ្យការប្រែប្រួលអាកាសធាតុក្លាយជាទិដ្ឋភាពស្តង់ដារមួយនៃការកសាងផែនការអភិវឌ្ឍន៍ និងការលើកថវិកា។

ទីពីរ ដូចមានចែងនៅក្នុង*ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា* "កម្ពុជាត្រូវអភិវឌ្ឍន៍ទៅរកសង្គមមួយ ដែលបៃតងជាងមុន បញ្ចេញកាបូនកម្រិតទាប ធន់នឹងអាកាសធាតុ មានសមធម៌ និរន្តភាព និងដែលផ្អែកលើចំណេះដឹង។" ដើម្បីសម្រេចចក្ខុវិស័យនេះបាន ប្រការសំខាន់គឺថា *ត្រូវបង្កើតក្របខ័ណ្ឌជាតិដ៏មានប្រសិទ្ធិភាព និងតម្លាភាព* ដើម្បីពិនិត្យតាមដានសកម្មភាពដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងពិនិត្យមើលវិភាជន៍ហិរញ្ញវត្ថុអាកាសធាតុ ស្របជាមួយអាទិភាពរបស់ជាតិ។

ទីបីនៅក្នុងបរិបទនេះ *កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូកាន់តែធំធេងរវាងអ្នកពាក់ព័ន្ធទាំងអស់ នឹងនាំមកនូវអនុភាពកាន់តែខ្លាំង*។កិច្ចប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនឹងមិនអាចសម្រេចទៅបានដោយរដ្ឋាភិបាលតែឯងឡើយ។ សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ត្រូវតែផ្តល់ការប្តេជ្ញាឲ្យបានពេញលេញ និងគាំទ្រដល់អាទិភាពជាតិទាំងនេះ។

*ទីបួនវាមានលក្ខណៈប្រាកដណាស់ដែលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានឥទ្ធិពលទៅលើគ្រប់វិស័យទាំងអស់មិនត្រឹមតែមកលើបរិស្ថាននោះទេ។ រូបសញ្ញាតំណាងសិក្ខាសាលាឆ្នាំនេះបង្ហាញពីអត្ថន័យនេះបានយ៉ាងល្អ។ដូច្នេះវិធានចម្រុះក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុគឺជាគន្លិះ ជាពិសេស ដើម្បីកសាងភាពធន់នៅចំពោះមុខហានិភ័យអាកាសធាតុនៅថ្នាក់មូលដ្ឋាន។ ការគាំទ្រ និងពង្រីកការអនុវត្តជាបន្ថែមគឺជាតម្រូវការចាំបាច់។* មេរៀនមួយក្នុងចំណោមមេរៀនដែលទទួលបានពីគម្រោងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគឺថា ភាពធន់របស់សហគមន៍មានភាពប្រសើរជាងមុន នៅពេលដែលពួកគេអាចកំណត់អាទិភាពរបស់ខ្លួន និងលើកស្នើដំណោះស្រាយចំពោះភាពងាយរងគ្រោះនៅចំពោះមុខការប្រែប្រួលអាកាសធាតុតាមវិធីចម្រុះ ។

ទីប្រាំក្នុងពេលដែលការយកចិត្តទុកដាក់លើកកំពស់ភាពធន់មានទំនោរផ្តោតច្រើនលើអ្នកក្រីក្រនៅជនបទកំណើនចំណាកស្រុកទៅទីក្រុងនានា ដោយសារតែការប្រែប្រួលអាកាសធាតុធ្វើឲ្យភាពធន់នៅទីក្រុងក៏ជាបញ្ហាមួយមានសារៈសំខាន់ផងដែរ។ យើងត្រូវធានាថា ទីក្រុងនានាទៅអនាគតត្រូវបានគ្រោងឡើងត្រឹមត្រូវ មាននិរន្តរភាព និងអាចឲ្យមនុស្សទាំងអស់ប្រើប្រាស់បាន។

នៅទីបញ្ចប់ ខ្ញុំសូមស្នើថា យើង *ពិនិត្យបញ្ហាការប្រែប្រួលអាកាសធាតុពីជ្រុងទស្សនៈយេនឌ័រផង។* ឥទ្ធិពលនៃហានិភ័យពីការប្រែប្រួលអាកាសធាតុនឹងបង្កើនវិសមភាពដែលមានស្រាប់ បង្កការគំរាមកំហែងមកលើបរចិញ្ចឹមជីវិត និងសន្តិសុខរបស់ស្ត្រី។ *ប៉ុន្តែ ស្ត្រីនៅក្នុងសហគមន៍ក៏អាចជាភ្នាក់ងារនាំមកនូវការប្រែប្រួលវិជ្ជមានផងដែរ និងជាអ្នកផ្តល់វិភាគទានដ៏សំខាន់ នៅក្នុងយុទ្ធសាស្ត្រនៃការបន្សាំសម្រាប់ការចិញ្ចឹមជីវិតប្រសិនបើ* ពួកគេមានឱកាសចូលរួមនៅក្នុងការស្វែងរកដំណោះស្រាយ និងធ្វើសេចក្តីសម្រេច ទាំងក្នុងការកំណត់គោលនយោបាយ និងការអនុវត្ត។

ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

អង្គការសហប្រជាជាតិបានដាក់ការប្រែប្រួលអាកាសធាតុនៅក្នុងរបៀបវារៈខ្ពស់មួយនៃការអភិវឌ្ឍពិភពលោក។ យើងមានការប្តេជ្ញាដើម្បីបន្តធ្វើជាដៃគូជាមួយវិស័យនានា ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកែលម្អការសម្របសម្រួល ពង្រឹងការយល់ដឹង និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ និងកៀងគរការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សមត្ថភាពនិងដោះស្រាយគម្លាតខាងគោលនយោបាយនិងស្ថាប័ន។

ការជួបជុំគ្នានាថ្ងៃនេះ ក្នុងនាមជាអ្នកឯកទេសប្រែប្រួលអាកាសធាតុះ ដែលរួមមានអ្នកវិទ្យាសាស្ត្រ រហូតដល់ប្រតិបត្តិករ អ្នកកសាងគោលនយោបាយរហូតដល់វិស័យឯកជន អ្នកស្រាវជ្រាវដល់ តំណាងពីសង្គមស៊ីវិល និងមេដឹកនាំសហគមន៍។ រួមជាមួយគ្នា យើងបានចាប់ផ្តើមចាត់ចែងវិធានការរបស់កម្ពុជាដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រយៈពេលពីរថ្ងៃកន្លះខាងមុខនឹងផ្តល់ឱកាសយ៉ាងច្រើនដើម្បីចែករម្លែកបទពិសោធន៍ដ៏សំបូរបែបនេះ។ ប៉ុន្តែវេទិកានេះក៏ស្តីអំពីការបញ្ចេញសកម្មភាពជាក់ស្តែងផងដែរ។ សូមឲ្យយើងបង្កើត និងពង្រឹងភាពជាដៃគូដែលមានជាក់លាក់នៅទីនេះ ដែលយើងត្រូវការដើម្បីអនុវត្តចក្ខុវិស័យនៃគំរូអភិវឌ្ឍន៍ដែលបញ្ចេញកាបូនទាប និងដែលធន់នឹងអាកាសធាតុសម្រាប់កម្ពុជា!

សូមអរគុណ!